**សុន្ទរកថា**

**ឯកឧត្តម អ៊ុង អឿន អភិបាលខេត្តបន្ទាយមានជ័យ**

**ថ្លែងក្នុងពិធីបើកសិក្ខាសាលា**

**ស្តីពី**

**វេទិកាផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល**

**ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ**

ថ្ងៃទី ២២-២៣ ខែកញ្ញា ឆ្នាំ ២០០៩

ខេត្តបន្ទាយមានជ័យ

---

គណៈអធិបតីជាទីគោរព !

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន !

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយជាអតិបរមាក្នុងការស្វាគមន៍ ចំពោះការអញ្ជើញចូលរួមរបស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់ ក្នុងសិក្ខាសាលាស្តីពី វេទិកាផ្លាស់ប្តូរយោបល់រវាងភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ ។

ជាមួយគ្នានេះដែរ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ និងសូមថ្លែងអំណរគុណដល់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ផ្តល់ដល់មន្ត្រី របស់មន្ទីរស្ថាប័នជំនាញ ផ្សេងៗជុំវិញខេត្តបន្ទាយមានជ័យយើងខ្ញុំមានឱកាសយល់ដឹង និងបានចូលរួមពិភាក្សានៅក្នុងសិក្ខាសាលានេះ ដែលខ្លួនខ្ញុំផ្ទាល់ចាត់ទុកការណ៍នេះថា ជាព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ខេត្តបន្ទាយមានជ័យ ដែលតែងតែ ខិតខំប្រឹងប្រែងរួមចំណែកពុំដែលអាក់ខាននៅក្នុងការអនុវត្តន៍កំណែទម្រង់ច្បាប់ និងតុលាការរបស់ រាជរដ្ឋាភិបាលកម្ពុជា ។

នៅព្រឹកនេះ ឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នឹងធ្វើបទអន្តរាគមន៍ ស្តីពីដំណើរការរបស់កំណែទម្រង់ច្បាប់ និងតុលាការ ហើយបន្ទាប់មក លោក **ឃ្លោក ជាអ៊ា** ប្រធានផ្នែកលើកកំពស់សិទ្ធិមនុស្ស និងមជ្ឈកម្ម នឹងធ្វើការបង្ហាញជូននូវការអភិវឌ្ឍន៍ និងភាពជឿនលឿន របស់កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ រហូតមកដល់ពេលបច្ចុប្បន្ននេះ ។

ប្រទេសកម្ពុជាបានងើបផុតពីជម្លោះ និងភាពតានតឹងខាងនយោបាយកន្លងមកហើយ ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាបានត្រៀមខ្លួនជាស្រេច ដើម្បីបោះជំហានឆ្ពោះទៅមុខ ជាមួយនិងមានភារកិច្ចបន្ទាន់ជាច្រើនក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ។ សកម្មភាពជាយុទ្ធសាស្ត្រ នៃដំណើរឆ្ពោះទៅមុខនេះរាជរដ្ឋាភិបាល

ចាំបាច់ត្រូវធ្វើកំណែទម្រង់លើវចនាសម្ព័ន្ធច្បាប់ និងតុលាការរបស់ខ្លួនដើម្បីធ្វើឱ្យដំណើរការ នៃការអភិវឌ្ឍប្រកបដោយប្រសិទ្ធភាព និងដើម្បីធ្វើឱ្យប្រជាពលរដ្ឋទទួលបានយុត្តិធម៌។

កំណែទម្រង់ច្បាប់ និងតុលាការគឺជាវិស័យអាទិភាពចាំបាច់បំផុត របស់រាជរដ្ឋាភិបាលកម្ពុជាដែលត្រូវធ្វើ។ ទោះបីជាយ៉ាងណាក៏ដោយគ្មានវិស័យណាមួយដែលអាចដំណើរការទៅបានតែឯកឯងនោះទេ។ យើងនឹងឃើញទាំងអស់គ្នា នៅថ្ងៃនេះបន្ទាប់ពីបទឱ្យទ្វេសនាមរបស់ឯកឧត្តម **សួង លាងហៃ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ លើសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ។ កំណែទម្រង់ច្បាប់ និងតុលាការ ទាមទារនូវការចូលរួមពីមន្ទីរស្ថាប័ន ជំនាញផ្សេងៗជុំវិញខេត្តក្នុងការអនុវត្តន៍នូវផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់ រាជរដ្ឋាភិបាលកម្ពុជា។ ហេតុដូច្នេះនៅថ្ងៃនេះយើងនឹងពិភាក្សាផ្លាស់ប្តូរយោបល់អោយបានផុលផុស អំពីបញ្ហាកំណែទម្រង់ច្បាប់ និងតុលាការខ្ញុំសង្ឃឹមថា សហការីមកពីមន្ទីរស្ថាប័ន ជំនាញផ្សេងៗ ជុំវិញខេត្តនឹងចូលរួមយ៉ាងសកម្មនៅក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់នេះ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន !

ខ្ញុំមានកិត្តិយសណាស់ ដែលសហការីរបស់យើងមានឱកាសទទួលបាននូវព័ត៌មាន នៃសកម្មភាពកំណែទម្រង់ច្បាប់និងតុលាការ ដែលជាយុទ្ធសាស្ត្រអាទិភាពរបស់រាជរដ្ឋាភិបាលនេះ ហើយនិងផ្តល់ឱកាសដល់យើងទាំងអស់គ្នាដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់នៅថ្ងៃនេះ។ ខ្ញុំសង្ឃឹមថា ឯកឧត្តម អស់លោក លោកស្រីអ្នកនាងកញ្ញានឹងប្រើប្រាស់ឱកាសនេះឱ្យបានល្អ ដើម្បីបន្ថែមការយល់ដឹងឱ្យកាន់តែប្រសើរថែមទៀតលើវិស័យកំណែទម្រង់ច្បាប់ និងតុលាការនេះ។ ចំពោះ ខេត្តបន្ទាយមានជ័យ យើងនេះ យើងមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តន៍សកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ និងបន្តនូវការគាំទ្រឱ្យបានខ្លាំងក្លាដើម្បីអនុវត្តន៍ការងារនេះ ហើយសង្ឃឹមថា សកម្មភាពកំណែទម្រង់ផ្សេងៗរបស់ ខេត្តបន្ទាយមានជ័យ

នឹងអាចច្របាច់បញ្ចូលទៅក្នុង ផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ របស់រាជរដ្ឋាភិបាលទាំងមូល ដើម្បីជួយជម្រុញដល់ការអនុវត្តន៍យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនេះ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា ជាទីគោរពរាប់អាន !

ដូចបានលើកឡើងពីខាងដើមហើយថា សិក្ខាសាលានេះត្រូវបានរៀបចំឡើងដើម្បី ពិភាក្សាផ្លាស់ប្តូរយោបល់ និងចែករំលែកទស្សនៈ និងបទពិសោធន៍ផ្សេងៗ នៃកំណែទម្រង់ច្បាប់ និងតុលាការក្នុងខណៈដែលរាជរដ្ឋាភិបាលកម្ពុជា កំពុងតែធ្វើដំណើរឆ្ពោះទៅមុខជាមួយនិង កម្មវិធីនយោបាយកំណែទម្រង់រដ្ឋ

ក្រោមការដឹកនាំដ៏ឈ្លាសវៃបំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាយើង។

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយ សូមអញ្ជើញឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់ចូលរួមស្តាប់ និងពិភាក្សាផ្តល់យោបល់ចំពោះការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការឱ្យបានហ្មត់ចត់ ដើម្បីជាទុនក្នុងការអនុត្តន៍ការងារកំណែទម្រង់ដ៏សំខាន់នេះ។ យើងខ្ញុំរង់ចាំនូវការចូលរួមយ៉ាងសកម្ម របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញា។

សូមអរគុណ ចំពោះការយកចិត្តទុកដាក់ របស់ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីអ្នកនាងកញ្ញា ទាំងអស់ ។

ខ្ញុំសូមប្រកាសបើកកម្មវិធីសិក្ខាសាលាពីពេលនេះតទៅ។